# II-ទីស្តីការគណៈរដ្ឋមន្ត្រី

## ១. អនុក្រឹត្យ

*រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ១៩៩៤*

### អនុក្រឹត្យលេខ ៥១ អនក្រ
### ស្តីពីការបង្កើត ១ កងពលតូចថ្មើរជើង

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះចៅក្រុងកម្ពុជាធិបតី ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ខែវិច្ឆិកាឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើតក្រសួងការពារជាតិ និង អគ្គសេនាធិការនៃកងទ័ពជាតិកម្ពុជា
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ

**សំរេច**

**មាត្រា ១ :** បង្កើត ១ កងពលតូចថ្មើរជើង ដោយផ្អែកលើមូលដ្ឋាន កងវរសេនាធំលេខ ៧០ ដែលកំពុង មាន បច្ចុប្បន្នហើយស្ថិតនៅក្រោមការដឹកនាំ បញ្ជាផ្ទាល់របស់អគ្គសេនាធិការ កងពលតូចថ្មើរជើងនេះ យកបញ្ញាសំគាល់ កងពលតូចថ្មើរជើងលេខ ៧០ ។

**មាត្រា ២ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ នាយអគ្គ សេនាធិការ នៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រីនៃក្រសួងពាក់ព័ន្ធ ត្រូវអនុវត្ត អនុក្រឹត្យ នេះ ដែលត្រូវមានប្រសិទ្ធភាព ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |